# ឱវាទ១០យ៉ាងរបស់ឪពុកនាងវិសាខា

នៅពេលនាងវិសាខាមានគូស្រករ,ឪពុករបស់នាងបានផ្តល់ឱវាទ១០យ៉ាង សម្រាប់ឱ្យនាងរិះគិត និងយកទៅប្រតិបត្តិក្នុងជីវិតគ្រួសារ ដើម្បីឱ្យបានសុខចម្រើន,ចៀសវាងជម្លោះ និងការប្រេះឆា ក្នុងឆាកជីវិតអាពាហ៍ពិពាហ៍។

**ឱវាទទាំង១០យ៉ាងនោះគឺៈ**

(ក).**ភ្លើង**

១.ហាមនាំយកភ្លើងក្នុងផ្ទះចេញទៅខាងក្រៅ

២.ហាមនាំយកភ្លើងខាងក្រៅចូលក្នុងផ្ទះ

៣.ថែរក្សាភ្លើងដោយប្រុងប្រយ័ត្ន

(ខ).**ការឱ្យ**

៤.ឱ្យរបស់ដល់ជនទាំងឡាយណាដែលឱ្យ ឬសងមកវិញ

៥.ហាមឱ្យរបស់ដល់ជនទាំងឡាយណាដែលមិនឱ្យឬមិនសងមកវិញ

៦.គប្បីឱ្យដល់ជនដែលឱ្យ ឬមិនឱ្យមកវិញ

(គ).**ការរៀបចំកាយ**

៧.អង្គុយដោយល្អ

៨.បរិភោគដោយល្អ

៩.ចូលដំណេកដោយល្អ

(ឃ).**ទេវតា**

១០.ត្រូវគោរពទេវតា ក្នុងផ្ទះ

## សូមពន្យល់ចំណុចនីមួយៗដូចតទៅ៖

**១.ហាមនាំយកភ្លើងក្នុងផ្ទះចេញទៅខាងក្រៅ** មានន័យថាហាមយករឿងរ៉ាវក្រុមគ្រួសារ ក្នុងផ្ទះទៅនិយាយឱ្យអ្នកជិតខាង ឬអ្នកក្រៅដឹង ឮ ដែលនាំឱ្យរឿងរ៉ាវក្នុងគ្រួសាររឹតតែរីកធំឡើង។

**២.ហាមនាំយកភ្លើងខាងក្រៅចូលក្នុងផ្ទះ** មានន័យថាប្រសិនបើបុរស ឬស្ត្រីអ្នកជិតខាងនិយាយដើមឪពុកក្មេក, នោះនាងមិនគួរនាំយកនូវអ្វីដែលនាងបានឮពីអ្នកដទៃនោះមកនិយាយសាឡើងវិញ«ថាអ៊ុំបេះអ៊ុំបុះ ឬថារឿងនោះមិនល្អសម្រាប់ឪពុក ដូច្នេះទេ» ព្រោះថាគ្មានភ្លើងណាអាចប្រៀបបាននឹងភ្លើងនេះឡើយ។

**៣.ថែរក្សាភ្លើងដោយប្រុងប្រយ័ត្ន** គប្បីយកចិត្តទុកដាក់ បំពោះឪពុកម្តាយក្មេក មានន័យថាភរិយា គួរគោរពកោតខ្លាចឪពុកម្តាយក្មេក ដូចជាភ្លើង ឬស្តេចនាគរាជ។

**៤.ឱ្យរបស់ដល់ជនទាំងឡាយណាដែលឱ្យ ឬសងមកវិញ** មានន័យថាបុគ្គល គប្បីឱ្យរបស់កម្ចីទៅតែជនណាដែលសងរបស់ដែលខ្ចីនោះមកវិញ។

**៥.ហាមឱ្យរបស់ដល់ជនទាំងឡាយណាដែលមិនឱ្យឬមិនសងមកវិញ** មានន័យថាហាមបុគ្គលមិនឱ្យយករបស់កម្ចី ទៅឱ្យជនណាដែលមិនសងរបស់នោះមកវិញ។

**៦.គប្បីឱ្យដល់ជនដែលឱ្យ ឬមិនឱ្យមកវិញ** សំដៅយការឱ្យដល់ញាតិក្រីក្រ, មានន័យថាបុគ្គលគួរឱ្យរបស់ណាដែលគួរឱ្យ ដល់ញាតិរបស់ខ្លួនដែលក្រីក្រ ឬមិត្តដែលមកសុំជំនួយ, ទោះជននោះមានរបស់សងវិញក្តី ឬមិនបានសងវិញក្តី គឺគប្បីឱ្យដោយការអនុគ្រោះ, បើអាចធ្វើទៅបាន។

**៧.អង្គុយដោយល្អ**(គឺមិនអង្គុយបំពីមុខឪពុកម្តាយក្មេក) មានន័យថានៅពេលភរិយា ឃើញម្តាយឬឪពុកក្មេក ឬប្តីរបស់នាង, គឺនាងគប្បីក្រោកឈរ មិនគប្បីនៅអង្គុយទេ។

**៨.បរិភោគដោយល្អ**(គឺបរិភោគបន្ទាប់ពីឪពុកម្តាយក្មេកបានបរិភោគហើយ) មានន័យថាភរិយាមិនគប្បីបរិភោគមុនឪពុកម្តាយក្មេក ឬប្តីរបស់នាងបានបរិភោគទេ។នាងគប្បីនៅបម្រើម្ហូបអាហារអ្នកទាំងនោះជាមុនសិន,ហើយប្រាកដថានៅពេលអ្នកទាំងនោះត្រូវបានខ្លួនខ្វល់ខ្វាយរៀបចំបប់ស្រេចបាច់ហើយ,ពេលនោះនាងខ្លួនឯងអាចបរិភោគបាន។

**៩.ចូលដំណេកដោយល្អ**(គឺចូលដំណេកក្រោយឪពុកម្តាយក្មេក) មានន័យថាភរិយាមិនគប្បីចូលដំណេកមុនឪពុកម្តាយក្មេកនាង ឬប្តីរបស់នាងទេ។នាងគប្បីបំពេញករណីយកិច្ច តូចធំ ដែលនាងជាប់ជំពាក់គេជាមុនសិន,បន្ទាប់មកសឹមនាងចូលគេងជាក្រោយដោយខ្លួនឯង។

**១០.គប្បីគោរពសំពះទេវតា ក្នុងផ្ទះ** (គឺគោរពស្វាមី និងឪពុកម្តាយក្មេករបស់ខ្លួន)មានន័យថាភរិយាគប្បីចាត់ទុកស្វាមី និងឪពុកម្តាយក្មេក របស់ខ្លួនដូចជាទេវតារបស់ខ្លួន។

ដូចនេះ,ទោះបីកាលៈទេសៈសម័យបច្ចុប្បន្ន អាចប្រែប្រួលផ្នែកអប់រំ,វប្បធម៌,ការងារ,សេដ្ឋកិច្ច,សង្គមកិច្ច និងនយោបាយ ខុសគ្នាក្នុងសម័យពុទ្ធកាលនៅប្រទេសឥណ្ឌាក្តី,ក៏ឱវាទ១០យ៉ាងរបស់ឪពុកនាងវិសាខានេះ ,មានបំណុចខ្លះ ក្នុងបំណោមបំណុចទាំង១០ នៅតែត្រឹមត្រូវ និងមានសុពលភាពអាចយកមកធ្វើការប្រតិបត្តិ ក្នុងសង្គមសម័យទំនើបបាន ដើម្បីសុភមង្គល ក្នុងជីវិតគ្រួសារជាតិខ្មែរយើង៕

ចប់ដោយសង្ខេប

រៀបរៀងដោយភិក្ខុ **សឿន ឧុទ្ធី**, M.A,Bdh,ITBMU)